ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ ៨៣៥ សជណ.ល

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## ជម្រាបជូន

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តរតនគិរី**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ**

**កម្មវត្ថុ ៖** របាយការណ៍ស្តីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥។

**យោង ៖** -របាយការណ៍ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥ របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន ឯកឧត្តម ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥ ទាក់ទងនឹងការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ១៦ ក្រុមហ៊ុន ស្ថិតក្នុងខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តកំពង់ស្ពឺ រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

**I-ខេត្តមណ្ឌលគិរី**

**១-ក្រុមហ៊ុន ខេ ភីស អ៊ិនវេសមេន (ខេមបូឌា)** (K PEACE Investment (Cambodia) Co.,Ltd)៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន ខេ ភីស អ៊ិនវេសមេន (ខេមបូឌា) (K PEACE Investment (Cambodia) Co.,Ltd) ស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃភ្នំណាមលៀរ ភូមិសាស្ត្រខេត្តមណ្ឌលគិរី បន្តនីតិវិធីលើផ្ទៃដីដោះស្រាយផលប៉ះពាល់រួច ទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៨០ (ប៉ែតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តមណ្ឌលគិរី និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ (បញ្ជាក់និយាមកា) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន ខេ ភីស អ៊ិនវេសមេន (ខេមបូឌា) (K PEAC Investment (Cambodia) Co.,Ltd) ស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃ ណាមលៀរ ភូមិសាស្ត្រខេត្តមណ្ឌលគិរី ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តមណ្ឌលគិរី គ្រប់គ្រង។

៤-កែសម្រួលអនុក្រឹត្យលេខ ១៣.អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាលស្តី ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត លេខ ២៨.អនក្រ.បក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោ ផ្ទៃដីទំហំ ៥០០ (ប្រាំរយ) ហិកតា ស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ភូមិសាស្ត្រ ខេ មណ្ឌលគិរី និងនិរាករណ៍អនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១។

៥-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទាន សេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមាន ផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

## ២-ក្រុមហ៊ុន សេដ្ឋិកុលា (SETHIKULA Co., Ltd) ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន សេដ្ឋិកុលា (SETHIKULA Co., Ltd) ស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃ ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី បន្តនីតិវិធ លើផ្ទៃដីដោះស្រាយផលប៉ះពាល់រួច ទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគ ពី ៩៩ (កៅសិបប្រាំបួន) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តមណ្ឌលគិរី និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន សេដ្ឋិកុលា (SETHIKULA Co., Ltd) ស្ថិតក្នុង តំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃភ្នំណាមលៀរ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តមណ្ឌលគិរី គ្រប់គ្រង។

៤-កែសម្រួលអនុក្រឹត្យលេខ ៣៧.អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព លើ ផ្ទៃដីទំហំ ៤.២៧៣ (បួនពាន់ពីររយចិតសិបបី) ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំណាមលៀរនិង ការធ្វើអនុបយោគដីសម្បត្តិសាធារណៈរបស់រដ្ឋ មកជាសម្បត្តិឯកជនរបស់រដ្ឋ។

៥-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដី សេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមាន ផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

## ៣-ក្រុមហ៊ុន វីឡា ឌីវេឡុបមេន (VILLA DEVELOPMENT CO.,Ltd) ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន វីឡា ឌីវេឡុបមេន (VILLA DEVELOPMENT CO.,Ltd) ស្ថិតនៅក្នុងតំបន់ដែន ជម្រកសត្វព្រៃភ្នំព្រេច ភូមិសាស្ត្រស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី បន្តនីតិវិធីដោយកាត់ផ្ទៃដី

មិនអាចដាំដុះបាន និងដីព្រៃទ្រនាប់ដងអូររួច ទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប)** ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តមណ្ឌលគិរី និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **វីឡា ឌីវេឡុបមេន** (VILLA DEVELOPMENT CO.,Ltd) ស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិសាស្ត្រស្រុកពេជ្រាដា ខេត្តមណ្ឌលគិរីឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តមណ្ឌលគិរី គ្រប់គ្រង។

៤-កែសម្រួលអនុក្រឹត្យលេខ **៦១ អនក្រ.បក** ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **៩៣ អនក្រ.បក** ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៧២៨ (ប្រាំពីររយម្ភៃប្រាំបី) ហិកតា** មានទីតាំងក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិសាស្ត្រស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។

**៤-ក្រុមហ៊ុន** Investment and Development DAI THANH ( Cambodia ) J.S.C LTD **៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន Investment and Development DAI THANH ( Cambodia ) J.S.C LTD ស្ថិតនៅស្រុកកែវសីមា ខេត្តមណ្ឌលគិរី បន្តនីតិវិធីដោយទុករយៈពេល **០៦ (ប្រាំមួយ) ខែ** សម្រាប់តាមដានវឌ្ឍនភាព និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ** និងចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តមណ្ឌលគិរី ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តត្រឹមត្រូវក្នុងរយៈពេលកំណត់ខាងលើ ក្រសួងបរិស្ថានត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសម្រេចដកហូត។

**៥-ក្រុមហ៊ុន លឹម រ៉ូយ៉ាល់ ជ័ញ ស្តុក** ( LIM ROYAL JOINT STOCK COMPANY LIMITED )៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន **លឹម រ៉ូយ៉ាល់ ជ័ញ ស្តុក** (LIM ROYAL JOINT STOCK COMPANY LIMITED) ក្នុងដែនជម្រកសត្វភ្នំព្រេច ភូមិសាស្ត្រ ខេត្តមណ្ឌលគិរី ស្ថិតនៅស្រុកកែវសីមា ខេត្តមណ្ឌលគិរី បន្តនីតិវិធីដោយទុករយៈពេល **០៦ (ប្រាំមួយ) ខែ** សម្រាប់តាមដានវឌ្ឍនភាព និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ** និងចុះកិច្ចសន្យាឡើងវិញ។

២-កែសម្រួលអនុក្រឹត្យលេខ **៧៩.អនក្រ.បក** ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាពលើផ្ទៃដីទំហំ ៩.០៦៨ **(ប្រាំបួនពាន់ហុកសិបប្រាំបី) ហិកតា** សម្រាប់ផ្តល់ជូនក្រុមហ៊ុន **លឹម រ៉ូយ៉ាល់ ជ័ញ ស្តុក** (LIM ROYAL JOINT STOCK COMPANY LIMITED) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម លើផ្ទៃដីចំនួន ៩.០៦៨ **(ប្រាំបួនពាន់ហុកសិបប្រាំបី) ហិកតា** រយៈពេល **៧០ (ចិតសិប) ឆ្នាំ**។

៣-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តមណ្ឌលគិរី ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តត្រឹមត្រូវក្នុងរយៈពេលកំណត់ខាងលើ ក្រសួងបរិស្ថាន ត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសម្រេចដកហូត។

**.ខេត្តរតនគិរី**

**១-ក្រុមហ៊ុន HOANG ANH ANDONG MEAS Co.,Ltd ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន HOANG ANH ANDONG MEAS Co.,Ltd ស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃលំផាត់ ភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនគិរី បន្តនីតិវិធីដោយកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ និងចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តរតនគិរី ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់លើការដាំព្រៃឈើឡើងវិញការពារការហូរច្រោះ និងអនុវត្តឲ្យបានត្រឹមត្រូវតាមផែនការមេ និងកិច្ចសន្យា។

**២-ក្រុមហ៊ុន ហ៊ាង អាញ លំផាត់ ខូអិលធីឌី (HOANG ANH LUMPHAT Co.,Ltd) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ហ៊ាង អាញ លំផាត់ ខូអិលធីឌី** (HOANG ANH LUMPHAT Co.,Ltd) ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃលំផាត់ ភូមិសាស្ត្រ ខេត្តរតនគិរី បន្តនីតិវិធីដោយកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ** និងចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តរតនគិរី ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់ ជាពិសេសអនុវត្តឲ្យបានត្រឹមត្រូវតាមផែនការមេ និងកិច្ចសន្យា។

**៣-ក្រុមហ៊ុន ដូនពេញ អាហ្គ្រីកូ (DAUN PENH AGRICO Co., Ltd) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ដូនពេញ អាហ្គ្រីកូ** (DAUN PENH AGRICO Co.,Ltd) ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃលំផាត់ ភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនគិរី បន្តនីតិវិធីដោយកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ** និងចុះកិច្ចសន្យាឡើងវិញបន្ទាប់ពីដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋរួច។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តរតនគិរី ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់ ជាពិសេសអនុវត្តឲ្យបានត្រឹមត្រូវតាមផែនការមេ និងកិច្ចសន្យា។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៤-ក្រុមហ៊ុន ម្កុដពេជ្រ អភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ម្កុដពេជ្រ អភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម** ស្ថិតនៅស្រុកលំផាត់ ខេត្តរតនគិរី បន្តនីតិវិធីដោយកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ** និងចុះកិច្ចសន្យាឡើងវិញក្រោយដោះស្រាយផលប៉ះពាល់រួច។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តរតនគិរី ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់ ជាពិសេសអនុវត្តឲ្យបានត្រឹមត្រូវតាមផែនការមេ និងកិច្ចសន្យា។

**.ខេត្តកំពង់ស្ពឺ**

**១-ក្រុមហ៊ុន ៩៩ អភិវឌ្ឍន៍ កសិកម្ម ខូអិលធីឌី (99 APHIVATH KASEKAM Co.,Ltd) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **៩៩ អភិវឌ្ឍន៍ កសិកម្ម ខូអិលធីឌី** (99 APHIVATH KASEKAM Co.,Ltd) ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រខេត្តកំពង់ស្ពឺ បន្តនីតិវិធីលើផ្ទៃដីដោះស្រាយ

ផលប៉ះពាល់រួច ទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) **ឆ្នាំ** មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ស្ពឺ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **៩៩ អភិវឌ្ឍន៍ កសិកម្ម ខូអិលធីឌី** (99 APHIVATH KASEKAM Co.,Ltd) ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រខេត្តកំពង់ស្ពឺ ឡើងវិញឲ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ **១៦.អនក្រ.បក** ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និង អនុក្រឹត្យលេខ **២២ អនក្រ.បក** ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគ ផ្ទៃដីទំហំ **១.៨០០ (មួយពាន់ប្រាំបីរយ) ហិកតា** ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រខេត្តកំពង់ស្ពឺ។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

## ២-ក្រុមហ៊ុន កំពង់ស្ពឺ ស៊ូហ្គើរ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន **កំពង់ស្ពឺ ស៊ូហ្គើរ** ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បន្តនីតិវិធីលើផ្ទៃដីដោះស្រាយផលប៉ះពាល់រួច ទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៩០ **(កៅសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ស្ពឺ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **កំពង់ស្ពឺ ស៊ូហ្គើរ** ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ឡើងវិញឲ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ **១៧.អនក្រ.បក** ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និង អនុក្រឹត្យលេខ **៤៧ អនក្រ.បក** ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៤.៧០០ (បួនពាន់ប្រាំពីររយ) ហិកតា** ស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

## ៣-ក្រុមហ៊ុន ហ្គ្រេត ហ្វៀល (ខេមបូឌា) អ៊ិនធើណេសិនណល លីមីតធីត (Great Field (Cambodia) International Limited)៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន ហ្គ្រេត ហ្វៀល (ខេមបូឌា) អ៊ិនធើណេសិនណល លីមីតធីត (Great Field (Cambodia) International Limited) ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រស្រុកឱរ៉ាល់

ខេត្តកំពង់ស្ពឺ បន្តនីតិវិធីលើផ្ទៃដីដោះស្រាយផលប៉ះពាល់រួច ទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ស្ពឺ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ហ្រ្គេត ហ្វៀល (ខេមបូឌា) អ៊ិនធើណេសិនណាល លីមីតធីត** (Great Field (Cambodia) International Limited) ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ឡើងវិញឲ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ ០៩.អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **១៩ អនក្រ.បក** ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៩.០៥៩ (ប្រាំបួនពាន់ហាសិបប្រាំបួន) ហិកតា** ស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៤-ក្រុមហ៊ុន** HLH Agriculture Cambodia Co.,Ltd **៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន HLH Agriculture Cambodia Co.,Ltd ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បន្តនីតិវិធីលើផ្ទៃដីដោះស្រាយផលប៉ះពាល់រួច ទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ស្ពឺ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន HLH Agriculture Cambodia Co.,Ltd ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ឡើងវិញឲ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ២៨.អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **៦២ អនក្រ.បក** ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ **៤០ អនក្រ.បក** ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១០។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៥-ក្រុមហ៊ុន** A2A Town ( Cambodia ) Co.,Ltd **៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន A2A Town ( Cambodia ) Co.,Ltd ធ្វើការវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិស្ថិតនៅក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" ភូមិសាស្ត្រ ខេត្តកំពង់ស្ពឺ បន្តនីតិវិធីលើផ្ទៃដីដោះស្រាយផលប៉ះពាល់រួច ទើបចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តកំពង់ស្ពឺ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់ ជាពិសេសអនុវត្តឲ្យបានត្រឹមត្រូវតាមផែនការមេ និងកិច្ចសន្យា។

**៦-ក្រុមហ៊ុន A 2 A TOWN ( CAMBODIA ) Co.,Ltd ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន A 2 A TOWN (CAMBODIA) Co., Ltd ធ្វើការវិនិយោគអភិវឌ្ឍន៍វិស័យទេសចរណ៍ ទីក្រុងធម្មជាតិ ទីលានវាយ កូនហ្គោល និងចៀរជ័រស្រល់ កាប់ឆ្ការ ផ្លាស់ប្តូរដាំដើមស្រល់បន្ថែមឡើងវិញ និងបង្កើតរោងចក្រ កែច្នៃផលិតផលជ័រស្រល់ ស្ថិតនៅភូមិសាស្ត្រ ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ បន្តនីតិវិធីលើផ្ទៃដីដោះស្រាយផលប៉ះពាល់រួច ទើបចុះកិច្ចសន្យា និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់ ជាពិសេសជំរុញក្រុមហ៊ុន A 2 A TOWN (CAMBODIA) Co., Ltd រៀបចំគម្រោងផែនការមេ និងចុះកិច្ចសន្យាឲ្យបានឆាប់។

**៧-ក្រុមហ៊ុន យេលឡូ ហ្វៀល (ខេមបូឌា) អ៊ិនធើណេសិនណាល លីមីតធីត (Yellow Field (Cambodia) International Limited) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **យេឡូ ហ្វៀល (ខេមបូឌា) អ៊ិនធើណាស្យូណាល់ លីមីតធីត** (Yellow Field (Cambodia) International Limited) ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បន្តនីតិវិធីលើផ្ទៃដីបានឈូសឆាយ និងដាំដុះរួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថានពិនិត្យលិខិតបទដ្ឋានបច្ចេកទេស និងមានវិធានការណ៍ចំពោះក្រុមហ៊ុន **យេឡូ ហ្វៀល (ខេមបូឌា) អ៊ិនធើណាស្យូណាល់ លីមីតធីត** (Yellow Field (Cambodia) International Limited ដែលបានឈូសឆាយដីមិនមានលិខិតអនុញ្ញាតកន្លងមក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**គង់ អរ ... សំរេច**

**ចម្លងជូន៖**
- -ក្រសួងមហាផ្ទៃ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងធនធានទឹក និងឧតុនិយម
- -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- -ក្រសួងរ៉ែ និងថាមពល
- -អង្គភាពប្រឆាំងអំពើពុករលួយ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- -សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
- -ឯកសារ-កាលប្បវត្តិ